នស/រកត/០៤០៧/១៥៤

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការកំណត់ព្រំប្រទល់រដ្ឋបាល រវាងខណ្ឌមានជ័យ រាជធានីភ្នំពេញ និង ស្រុកគៀនស្វាយ ខេត្តកណ្តាល

~~~~~~~

**យើង**

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជាឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-**

ត្រូវបានកំណត់ព្រំប្រទល់រដ្ឋបាលរវាងខណ្ឌមានជ័យ រាជធានីភ្នំពេញ និង ស្រុកគៀនស្វាយ ខេត្តកណ្តាល ដូចតទៅ :

ខ្សែព្រំប្រទល់គឺ ចាប់ផ្តើមចេញពីទន្លេបាសាក់រត់ទៅទិសឥសាន្ត ដោយបត់បែនតាមអ័ក្សនៃព្រែកប្រា រួចឆ្លងកាត់ស្ពានព្រែកប្រា ហើយបន្តតាមអ័ក្សនៃព្រែកប្រានេះដដែលរហូតដល់បឹងប្រា រួចរត់តាមខ្សែកណ្តាល បណ្តោយបឹងប្រានេះរហូតដល់ចំណុចដែលមាននិយាមកា (៤៩៦២០០.១២៧១៧៧៨) ទើបប្រែទិសរត់ត្រង់ឆ្ពោះទៅទិសខាងជើង រហូតដល់ចំណុច B ដែលមាននិយាមកា (៤៩៦២០០.១២៧៥៦២០) ចំណុចនេះ ស្ថិតខាងជើងផ្លូវ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
~~~~~~~

ជាតិលេខ ១ ចំងាយ ៣០ម ពីអ័ក្សផ្លូវ រួចខ្សែព្រំប្រទល់រត់បត់ទៅទិសខាងលិចស្របតាមផ្លូវជាតិលេខ ១ (រត់ខាងជើងផ្លូវជាតិលេខ ១ ដោយរក្សាចំងាយ ៣០ម ពីអ័ក្សផ្លូវ) រហូតដល់ចំណុច A ដែលមាននិយាមកា (៤៩៥៨៨០.១២៧៥៩៩០) ចំណុចនេះស្ថិតខាងជើងផ្លូវជាតិលេខ ១ ចំងាយ ៣០ម ពីអ័ក្សផ្លូវ និង ស្ថិតនៅជើងទំនប់ហែមចំរើនខាងកើត រួចប្រែទិសរត់ទៅខាងជើង តាមជើងទំនប់ហែមចំរើនផ្នែកខាងកើតរហូតដល់ចំណុចដែលមាននិយាមកា (៤៩៥៨៨០.១២៧៥៨០៥) ចំណុចនេះ ស្ថិតខាងកើតឈៀងខាងជើងនៃចុងទំនប់ហែមចំរើន ចុងបញ្ចប់ខ្សែព្រំប្រទល់រត់ចូលទៅក្នុងទន្លេមេគង្គក្រោម ដូចបានកំណត់នៅលើផែនទីដែលមានមាត្រដ្ឋាន ១:១០.000 UTM Zone 48 , Datum WGS84 ដែលវាស់វែងដោយឧបករណ៍ GPS Gormin Etrex Teodolite Wild T2 របស់នាយកដ្ឋានភូមិសាស្ត្រ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៥ ។

មាត្រា២.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣.-

សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

ពរល. ០៧០៤. ១៦៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៧

លេខៈ ៣៧៦ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន